ថ្ងៃអាទិត្យ ទី ១៣ ខែមិនា ២០០៥

## លិខិតចំហជូនមកលោក សំដាចម៏ ហ៊ុន សែន នាយករដ្ឋមន្ត្រីកញ្ចប់នៃកម្ពុជា

ខ្ញុំបានឮលោក សំដាចម៏ ហ៊ុន សែន ប្រកាសថា រាជរដ្ឋាភិបាលកញ្ចប់អាណត្តិទី៣ នេះជារាជរដ្ឋាភិបាលធារាសាស្ត្រ ។

បើតាមយោបល់របស់ខ្ញុំផ្ទាល់ ដើម្បីឲ្យប្រទេសខ្មែរក្លាយទៅជាប្រទេសអ្នកមាន ដោយកាត់បន្ថយភាពក្រីក្រឲ្យអស់ពីប្រទេសនោះ សូមលោក សំដាចម៏ ហ៊ុន សែន កុំដាក់ឈ្មោះរាជរដ្ឋាភិបាលអាណត្តិទី៣ជារាជរដ្ឋាភិបាលធារាសាស្ត្រអី ! សុំដាក់ថារាជរដ្ឋាភិបាល **បង្គន់អាចម៏** វិញដើម្បីទាក់ទាញអ្នកទេសចរបរទេសឲ្យមកទស្សនាកំសាន្តប្រទេសខ្មែរឲ្យបានច្រើនជាអតិបរិមា: ព្រោះស្រុកខ្មែរសម្បូរណ៏ប្រាសាទបូរាណនឹងទីរមណ្ឌានច្រើនឥតគណនា តែនៅកន្លែងនោះមិនមានបង្គន់អាចម៏អានាមយ័ទេ ដែលជាផលពិបាកមួយធ្វើឲ្យអ្នកទេសចរអស់ឯកមិនចង់មកកំសាន្តចំណាយប្រាក់កាសនៅប្រទេសកម្ពុជាទេដោយសារតែខ្វះបង្គន់អាចម៏នេះ ។ សូមលោក សំដាចម៏ ហ៊ុន សែន ជ្រាបថាទេសចរជាប្រភពឧសហាកម្មដ៏ធំមួយដែលនាំចំណូលមកឲ្យប្រជារាស្ត្រខ្មែរ ។

បើលោក សំដាចម៏ ហ៊ុន សែន យល់ស្របតាមយោបល់របស់ខ្ញុំ សូមសំដាចម៏ដាក់ឈ្មោះរាជរដ្ឋាភិបាលទី៣នេះជារាជរដ្ឋាភិបាលបង្គន់អាចម៏ទៅ ហើយចាប់សង់បង្គន់អាចម៏ឲ្យបានគ្រប់ចំនួនទៅតាមប្រាសាទនឹងទីរមណ្ឌាននានាលើទូទាំងប្រទេសខ្មែរ ហើយនៅលើខ្លោងទ្វារចូលទៅបង្គន់អាចម៏និមួយៗ សុំឲ្យសរសេអក្សរធំៗដើម្បីទាក់ទាញភ្ញៀវទេសចរនឹងអ្នកវិនិយោគទុន ដោយដាក់ថា : **បង្គន់អាចម៏ សំដាចម៏ ហ៊ុន សែន** ដោយមានបង្គន់អាចម៏អានាមយ័គ្រប់ក្រាន់យ៉ាងដូច្នេះ ឧសហាកម្មទេសចរប្រាកដជារីកចំរើន ប្រទេសខ្មែរក៏ក្លាយទៅជាប្រទេសអ្នកមាន ប្រជាជនខ្មែរជាអ្នកក្រីក្រក្រោមបន្ទាត់ក្រីក្រចំនួន ៤៦%នឹងធ្លាក់មក ០០% វិញនៅពេលអនាគតយ៉ាងខ្លីខាងមុខនេះមិនខានឡើយ ហើយលោក សំដាចម៏ ហ៊ុន សែន អាចនឹងមានប្រជាប្រិយ៏ភាព អាចនឹងក្រាញតោងអំណាចអាចធ្វើជានាយករដ្ឋមន្ត្រីកញ្ចប់អស់មួយជីវិតទៀតផង ។

ប្រពន្ធធារាសាស្ត្រគឺជាប្រពន្ធទំនប់ប្រឡាយនាំទឹកបញ្ចូលស្រែចំការដោយបង្ហូរទឹកបញ្ចូលស្រែចំការដោយមិនពឹងផ្អែកទៅលើម៉ាស៊ីនបូមទឹកឡើយ ។ បើគ្មានប្រភពទឹកទេ មិនចាំបាច់នាំគ្នានឹងកែនគ្នាជីកប្រឡាយសម្រាប់ត្រងទឹកភ្លៀងហើយថាធ្វើប្រពន្ធធារាសាស្ត្រជូនកសិករនោះទេ នាំតែឲ្យកសិករខ្មែរខាតបង់កំឡាំងនឹងរដ្ឋខាតថវិកាឥតប្រយោជន៏ ព្រោះបើទឹកភ្លៀងដក់នៅក្នុងស្រែរីងស្ងួតអស់ ទឹកនៅដក់ក្នុងប្រឡាយក៏រីងស្ងួតដែរ ។ បើមិនជឿរខ្ញុំ សូមលោកសម្តចម៏ ហ៊ុន សែន ក្រឡេកមើលទៅក្រោយវិញ នៅសម័យខ្មែរក្រហម ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលលោក សំដាចម៏ ហ៊ុន សែន ជាខ្មែរក្រហមមួយរូបក្នុងរបបនោះដែរ តើខ្មែរក្រហមសម្លាប់ប្រជាជនខ្មែរអស់ប៉ុន្មានលាននាក់ ក្នុងការបង្ខំឲ្យជីកលើកដីទប់ទំនប់នឹងជីកប្រឡាយពេញទាំងផ្ទៃប្រទេសកម្ពុជាប្រជាធិប្បតេយ្យនាពេលនោះ ។ មានតែលោក សំដាចម៏ ហ៊ុន សែន ជាខ្មែរក្រហមនោះទេដែលដឹងថាមានទំនប់នឹងប្រឡាយខ្មែរក្រហមនៅសល់ប៉ុន្មានជូនដល់កសិករខ្មែរមកដល់សព្វថ្ងៃនេះ ។

ក្នុងសម័យសង្គមរាស្ត្រនិយម ឬ សង្គមរាស្ត្រយំ ក្រោមការដឹកនាំរបស់លោក សំដាចម៏ នរោត្តម សីហនុ ប្រមុខរដ្ឋអស់មួយជីវិត-តែងតាំងខ្លួនឯងឬអង្គុយលើចង្អេរលើកខ្លួនឯង-ការធ្វើនយោបាយទឹកក៏មានសន្ទុះខ្លាំងក្លាណាស់ដែរ តែគ្មានបានប្រយោជន៏អ្វីសោះ ។ តែប្រជារាស្ត្រខ្មែរនៅតែធ្វើស្រែប្រវាស់ជាមួយមេឃឬប្រវាស់ជាមួយទឹកភ្លៀងរៀងរហូតមកដល់សព្វថ្ងៃនេះ ។

តែលោក សំដាចម៏ នរោត្តម សីហនុ ឆ្លាតណាស់នៅមានទេពកោសល្យមួយថ្មីទៀតប្រសប់ណាស់ដើម្បីធ្វើប្រជាភិថុតិឬបញ្ឆើចបញ្ឆើរប្រជារាស្ត្រឲ្យជឿរអង្គសំដាចម៏ថា ជាអ្នកមានបុណ្យមហិទ្ធិរិទ្ធខ្លាំងពូកែខ្លាំងណាស់ អាចធ្វើឲ្យមេឃបង្អុះទឹកភ្លៀងបានតាមចិត្តចង់ដើម្បីឲ្យកសិករខ្មែរធ្វើស្រែចំការគ្រប់ពេលវេលា ។ ម្តេចក៏លោក សំដាចម៏ឪមិនធ្វើឲ្យប្រទេសខ្មែរទៅជាប្រទេសអ្នកមានទៅ ? ហេតុដូចម្តេចបានជាប្រទេសខ្មែរទៅជាប្រទេសក្រជាងគេទៅវិញ?

នៅពេលធ្វើពិធីបួងសួងសុំទឹកភ្លៀងម្តងៗ លោកសំដាចម៏ឪ នរោត្តម សីហនុ តែងតែកោរប្រកេស" កោរក្បាល" ។ ពិធីបួងសួងនេះធ្វើនៅចុងរដូវភ្លៀងឬក្នុងខែកញ្ញាឬខែបុណ្យភ្ជុំបិណ្ឌដែលមានភ្លៀងធ្លាក់ជោកជាំជានិច្ចជាកាល គួរឲ្យអស្ចារ្យណាស់ ។

ហេតុដូច្នេះ បើលោក សំដាចម៏ ហ៊ុន សែន ចង់បានទឹកឲ្យកសិករខ្មែរធ្វើស្រែកុំឲ្យ

ខ្វះទឹកជាយថាហេតុចាប់តាំងពីដើមខែពិសាខនេះទៅ ដោយមិនបាច់ចំណាយថវិកាទៅសាងសង់ប្រព័ន្ធធារាសាស្ត្រឥតប្រយោជន៍ស្អីគេនោះទេ ។ សូមលោក សំដាចម៏ ហ៊ុន សែន បញ្ជាទៅលោក សំដាចម៏ ទេព វង់ ខ្មែរយៀកមិញ ជាសង្ឃរាជ ទៅយាងលោក សំដាចម៏ នរោត្តម សីហនុ ជាវរៈក្សត្រ័ មកធ្វើពិធីបួងសួងសុំទឹកភ្លៀងនៅឱកាសបុណ្យចូលឆ្នាំថ្មីខ្មែរនាខែចេត្រខាងមុខនេះ មេឃនឹងអាចបង្អុរជាទឹកភ្លៀងមកថ្វាយលោក សំដាចម៏ នរោត្តម សីហនុ ជាវរៈក្សត្រ័មិនខានឡើយ ។ ដោយសារបារមីនេះកសិករខ្មែរអាចធ្វើស្រែបានផលគ្រប់ៗគ្នាមិនជួបប្រទះនឹងការរាំងស្ងួតឡើយ ។

ដោយសង្ឃឹមទៅលើមហិទ្ធិរិទ្ធនេះ លោក សំដាចម៏ ហ៊ុន សែន អាចយកថវិការសាងសង់ប្រពន្ធធារាសាស្ត្រទៅសាងបង្គន់អាចម៏វិញបានហើយ តែសូមកុំភ្លេចប្រកាសប្រាប់ប្រជារាស្ត្រថា: រាជរដ្ឋាភិបាលអាណត្តិទី៣នេះជារដ្ឋាភិបាល **បង្គន់អាចម៏** ហើយដាក់ផ្លាកលើក្លោងទ្វារបង្គន់និមួយៗថា:

# ” បង្គន់អាចម៏ សំដាចម៏ ហ៊ុន សែន ”

គួរពុំគួរសូមលោក សំដាចម៏ ហ៊ុន សែន ទទួលការគោរពនឹងការរាប់អានអំពីខ្ញុំ ។

ខែម ខៀវ

ចម្លងថ្វាយនឹងជូនមក ៖
- លោក សំដាចម៏ នរោត្តម សីហនុ ជា មហាវរៈក្សត្រ័
- លោក សំដាចម៏ ទេព វង់ ខ្មែរយៀកមិញ ជា សង្ឃរាជ